មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៥-០១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០១០៦/០៤១ ស្តីពីការតែងតាំងឯកឧត្តម ០២ រូប ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥៤៤

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧០ ស្តីពីការតែងតាំងឯកឧត្តម ០៦ រូប ជាទីប្រឹក្សា សម្តេច **ហេង សំរិន** អនុប្រធានទី ១ រដ្ឋសភានីតិកាលទី ៣ មានឋានៈស្មើ រដ្ឋលេខាធិការ ៥៤៥

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧១ ស្តីពីការតែងតាំង ឯកឧត្តម **ខឹម សារិន** ជា ឧកញ៉ា ៥៤៦

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧២ ស្តីពីការតែងតាំង លោក **វ័ន្ត សុវណ្ណារ៉ា** និង លោកឧត្តមសេនីយ៍ត្រី **ឡាច ទ៉ាន់** ជា ឧកញ៉ា ៥៤៧

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៤ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០៣ រូប ក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ ៥៤៨

០៩-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៥ ស្តីពីការតម្លើងឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ចំនួន ០២ រូប ៥៤៩

០៩-០២-២០០៦ -ព្រះរាជក្រឹត្យនស/រកត/០២០៦/០៧៦ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ឯក ជូនឯកឧត្តមឧត្តមសេនីយ៍ទោ **ហាក់ សាមុត** ៥៥០

១១-០២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០២០៦/០៧៩ ស្តីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្តម ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ៥៥១

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៩-០២-២០០៦ -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៥២

០៧-០២-២០០៦ -អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៥៣
០៧-០២-២០០៦ -អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥៥៧
១០-០២-២០០៦ -អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៥៨
១០-០២-២០០៦ -អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦០
១៤-០២-២០០៦ -អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦១

III~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

០៨-០២-២០០៦ -ប្រកាសលេខ ០៩ កយ.ប្រក/០៦ ស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការពង្រាងឱ្យលក់ដោយខុសច្បាប់ ៥៦២

២~ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៩-០២-២០០៦ -ប្រកាសលេខ ១៧១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ភ្នំពេញ សាច់ផ្លាយ ខមផេនី លីមីធីត** បង្កើតរោងចក្រ " ប្លាស្ទិក " ដែលមានឈ្មោះថា " ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត " ៥៦៧
០៩-០២-២០០៦ -ប្រកាសលេខ ១៧២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ហ៊ុយចៀន (ខេមបូឌា)ខប** បង្កើតរោងចក្រ" ផលិតស្បែកជើង " ដែលមានឈ្មោះថា " ហ៊ុយចៀន (ខេមបូឌា) ខប " ៥៦៩
០៩-០២-២០០៦ -ប្រកាសលេខ ១៧៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **អេច ២ ហ្គាមេន** បង្កើតរោងចក្រ" កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " អេច ២ ហ្គាមេន " ៥៧១
១០-០២-២០០៦ -ប្រកាសលេខ ១៨៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **តាលិន ហ្គាមេន អ៊ិនដាសស្ទ្រី (ខេមបូឌា)** បង្កើតរោងចក្រ" កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " តាលិន ហ្គាមេន អ៊ិនដាសស្ទ្រី (ខេមបូឌា)" ៥៧៣

៣~ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

០១-០២-២០០៦ -ប្រកាសលេខ១៥៩អយក.ប្រក ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន "ទូនហ្វា II" ស្ថិតនៅក្នុង សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ៥៧៥
០១-០២-២០០៦ -ប្រកាសលេខ ១៦០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "បុសលាវ" ស្ថិតនៅក្នុង ឃុំបុសលាវ ស្រុកក្រចេះ ខេត្ត ក្រចេះ ៥៧៧

០១-០២-២០០៦ -ប្រកាសលេខ ១៦១ អយក.ប្រក ស្តីពីការពង្រីកអនុវិទ្យាល័យ "ហ៊ុនសែន ស្នួល" ទៅជាវិទ្យាល័យ "ហ៊ុនសែន ស្នួល" ស្ថិតនៅក្នុង ឃុំស្នួល ស្រុកស្នួល ខេត្ត ក្រចេះ ៩៧៨
០១-០២-២០០៦ -ប្រកាសលេខ ១៦២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "ខ្សាច់អណ្តែត" ស្ថិតនៅក្នុង ឃុំខ្សាច់អណ្តែត ស្រុកឆ្លូង ខេត្តក្រចេះ ៩៧៩
០១-០២-២០០៦ -ប្រកាសលេខ ១៦៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "គោលាប់" ស្ថិតនៅក្នុង ឃុំគោលាប់ ស្រុកក្រចេះ ខេត្តក្រចេះ ៩៨០

៤_លិខិតរបស់រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១៨-០១-២០០៦ -លិខិតលេខ ២៣៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី អ៊ិន អាយ ខូ អិលធីឌី** ៩៨១
១៨-០១-២០០៦ -លិខិតលេខ ២៣៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្រឹស្តាល់ អាគ្រោ** ៩៨៣
១៨-០១-២០០៦ -លិខិតលេខ ២៣៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខាមីណេគ ខនស្ត្រាក់សិន** ៩៨៥
១៨-០១-២០០៦ -លិខិតលេខ ២៣៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ទៀល ហ្គ្រីន** ៩៨៧
១៨-០១-២០០៦ -លិខិតលេខ ២៤១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឡូធើស ខេមបូឌាន_អ៊ិនធើណេសិនណល** ៩៨៩
១៨-០១-២០០៦ -លិខិតលេខ ២៤៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូច រ៉ត់ (ខេមបូឌា) អិនធើប្រាយ** ៩៩១
១៨-០១-២០០៦ -លិខិតលេខ ២៤៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **សុខ លីញ អ៊ីមផត អិចផត** ៩៩៣
១៨-០១-២០០៦ -លិខិតលេខ ២៤៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល ស៊ី ស៊ីខេ អ៊ិនធើណេសិនណល** ៩៩៥
១៨-០១-២០០៦ -លិខិតលេខ ២៤៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាយហ្គន ឌីវេឡុបមេន គ្រុប** ៩៩៧

១៨-០១-២០០៦ -លិខិតលេខ ២៤៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ដាប់បែលយូ ធី ស៊ី ឌីវេឡុបមេន** ៩៩៩

១៩-០១-២០០៦ -លិខិតលេខ ២៥១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អឹមផ្លាយហ្វូន** ១០០១

១៩-០១-២០០៦ -លិខិតលេខ ២៥៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចឺ.ឌី.ទ៉ាយ (ចឺ ឌី យូ) ត្រេឌីង** ១០០៣

ព្រះរាជក្រឹត្យ

នស/រកត/០២០៦/០៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូន

- ឯកឧត្តមឧត្តមសេនីយ៍ទោ ចាក់ សាវុធ អត្តលេខ ០០០៥១១

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦៧-០៨១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៦

លេខៈ ៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

នស/រកត/០២០៦/០៧៩

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

H.E Fumiaki TAKAHASHI

ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ចារ.០៦០៧.០៥៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៦

លេខ: ៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១១១...អនក្រ...បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៥រូប ដែលបានឧបត្ថម្ភថវិកា ជួយកសាងមន្ទីរពិសោធន៍ នៅរាជធានីភ្នំពេញ និងអគារសិក្សា ០១ខ្នង បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ នៅវិទ្យាល័យ សុខ អាន ១ ឧសភា ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានព្រះនាម និងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-លោក **ខួន ទ៉ាន់ចន្ធី**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ១១.០០០ ដុល្លារ
២-ព្រះតេជគុណ **ខែម សុខ**	ព្រះអនុគណស្រុកត្រាំកក់	បច្ច័យចំនួន ១០.៥០០ ដុល្លារ
៣-លោក **សេខ សាទន**	នៅក្រុងភ្នំពេញ	ថវិកាចំនួន ១១.២០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក **ឈឹម ផេង**	នៅខេត្តតាកែវ	ថវិកាចំនួន ៥.៧០០ ដុល្លារ
២-លោក **អ៊ីង មឿន**	នៅខេត្តតាកែវ	ថវិកាចំនួន ៥.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ៨៩រូប នៃក្រសួងកិច្ចការនារី ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោមនេះ :-

ក-មេដាយមាសការងារ :

១-ឯកឧត្តម	សឿ ច័ន្ទហ៊ីរ	អគ្គនាយករដ្ឋបាល និងកិច្ចការទូទៅ
២-លោកជំទាវ	ជូ ច័ន្ទអេង	អគ្គនាយកអភិវឌ្ឍសង្គម
៣-លោកស្រី	ខិក កនធឿន	អគ្គនាយករងរដ្ឋបាល និងកិច្ចការទូទៅ
៤-លោកស្រី	ខឹន ស៊ីវ៉េត	អគ្គនាយករងអភិវឌ្ឍសង្គម
៥-លោក	ខឹម សោភ័ណ	ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក
៦-លោកស្រី	ឌី វ៉ានី	ប្រធាននាយកដ្ឋានព័ត៌មាន
៧-លោកស្រី	ហ៊ូ និរមិត្តា	ប្រធាននាយកដ្ឋានស្ត្រី និងសុខភាព
៨-លោកស្រី	ញាណ សុចិត្រា	ប្រធាននាយកដ្ឋានសមភាពយេនឌ័រ
៩-លោកស្រី	ឡុង និមល	ប្រធាននាយកដ្ឋានស្ត្រី និងអប់រំ
១០-លោក	យឹម សាមន	អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ និងផ្គត់ផ្គង់
១១-លោកស្រី	អ៊ុត សន	ប្រធានមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគីរី
១២-លោកស្រី	ញឹក សារិ	ប្រធានមន្ទីរកិច្ចការនារី ខេត្តបន្ទាយមានជ័យ
១៣-លោកស្រី	នួច សារ៉ុម	ប្រធានមន្ទីរកិច្ចការនារី រាជធានីភ្នំពេញ
១៤-លោកស្រី	ឯម ប៊ុណ្ណា	ប្រធានមន្ទីរកិច្ចការនារី ខេត្តពោធិសាត់

១៥-លោកស្រី ស្វស សារ៉ាម ប្រធានមន្ទីរកិច្ចការនារី ខេត្តកណ្តាល
១៦-លោកស្រី ឯម ផល្លា ប្រធានមន្ទីរកិច្ចការនារី ខេត្តព្រៃវែង
១៧-លោកស្រី ស៊ឹម ម៉ារី អនុប្រធានមន្ទីរកិច្ចការនារី ខេត្តបាត់ដំបង

ខ-មេដាយប្រាក់ការងារ :

១-លោក គឹម សុន អគ្គនាយករងរដ្ឋបាល និងកិច្ចការទូទៅ
២-លោកស្រី ជុំតលាង ម៉ាន់នី អគ្គនាយករងសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ច
៣-លោកស្រី កែត ម៉ារឌី ប្រធាននាយកដ្ឋានការពារផ្លូវច្បាប់
៤-លោកស្រី អ៊ុក ឈានី អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ
៥-លោកស្រី ស៊ុន វណ្ណា អនុប្រធាននាយកដ្ឋានការពារផ្លូវច្បាប់
៦-លោកស្រី ម៉ុនឈិត វាសនា អនុប្រធាននាយកដ្ឋានអភិវឌ្ឍសេដ្ឋកិច្ច
៧-លោកស្រី នុំ បូផារី អនុប្រធាននាយកដ្ឋានស្ត្រី និងការអប់រំ
៨-លោកស្រី តែ ទូចលីម អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ
៩-លោកស្រី ខៀង ទេវានីភាព អនុប្រធាននាយកដ្ឋានស្ត្រី និង សុខភាព
១០-លោកស្រី ឌុក ម៉ាឡានី ប្រធានការិយាល័យថវិកា នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
១១-លោកស្រី ពៅ សុភាព អនុប្រធានមន្ទីរកិច្ចការនារី ខេត្តស្វាយរៀង
១២-លោកស្រី ជ្រើយ ចានី អនុប្រធានមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគិរី
១៣-លោកស្រី ឯម ផល្លាមុន្នី អនុប្រធានមន្ទីរកិច្ចការនារី ខេត្តសៀមរាប
១៤-លោកស្រី សន សុខា អនុប្រធានមន្ទីរកិច្ចការនារី ខេត្តស្ទឹងត្រែង
១៥-លោកស្រី ភាន់ ឈៀង អនុប្រធានមន្ទីរកិច្ចការនារី ខេត្តរតនគិរី
១៦-លោកស្រី សៅ ភាន អនុប្រធានមន្ទីរកិច្ចការនារី ក្រុងព្រះសីហនុ
១៧-លោកស្រី សោម សាគួ អនុប្រធានមន្ទីរកិច្ចការនារី ខេត្តក្រចេះ
១៨-លោកស្រី ឡុក សុម៉ារ៉ាម៉ែត អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកោះកុង
១៩-លោកស្រី យឹម ភារី អនុប្រធានមន្ទីរកិច្ចការនារី ខេត្តតាកែវ
២០-លោកស្រី ខៀង រីម អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកណ្តាល
២១-លោកស្រី នង អាល័យ អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ធំ
២២-លោកស្រី ឯក សុវណ្ណនារៈ អនុប្រធានមន្ទីរកិច្ចការនារី ខេត្តឧត្តរមានជ័យ
២៣-លោកស្រី វស់ សុភ័ក្ត្រ អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម
២៤-លោកស្រី ម៉ែន អេន ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ម៉ារីរណឫទ្ធិ ខេត្តកំពង់ឆ្នាំង
២៥-លោកស្រី នួច សាគន្ធ ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ សម្តេចម៉ែ ខេត្តកំពង់ស្ពឺ
២៦-លោកស្រី ពត សុផា ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ប៊ុនរ៉ានីហ៊ុនសែន ខេត្តពោធិ៍សាត់
២៧-លោកស្រី អ៊ុំ រី ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ព្រះកុសុមៈ ខេត្តកំពង់ចាម

ខ-មេដាយសំរិទ្ធការងារ :

១-លោក តី សុគន្ធ អនុប្រធាននាយកដ្ឋាន សមភាពយេនឌ័រ
២-លោកស្រី ជា ហ៊ីង អនុប្រធាននាយកដ្ឋានសមភាពយេនឌ័រ
៣-លោកស្រី ឃ្លោក ម៉េងថុល អនុប្រធាននាយកដ្ឋានស្ត្រី និង សុខភាព
៤-លោកស្រី ម៉ែន ថេន អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ឆ្នាំង
៥-លោកស្រី ចាល់ យឿន អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ឆ្នាំង
៦-លោកស្រី ឡុង សុឃាទី អនុប្រធានមន្ទីរកិច្ចការនារី ក្រុងប៉ៃលិន
៧-លោក ឆឹន សេដ្ឋា អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពត

៨-លោកស្រី	ឈឹម ស៊ីណា	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តពោធិសាត់
៩-លោកស្រី	គង់ សាឡួន	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តព្រៃវែង
១០-លោកស្រី	អ៊ុង សំអុល	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តព្រះវិហារ
១១-លោកស្រី	តិន ទេវ្យ	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តបន្ទាយមានជ័យ
១២-លោកស្រី	ជា ស៊ីយ៉េត	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តមណ្ឌលគិរី
១៣-លោកស្រី	ចន យឿន	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ស្ពឺ
១៤-លោកស្រី	អ៊ុំ សុផល	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ស្ពឺ
១៥-លោក	អ៊ុក ណារិន	អនុប្រធានមន្ទីរកិច្ចការនារី រាជធានីភ្នំពេញ
១៦-លោកស្រី	ខ្លូង សុខា	អនុប្រធានមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម
១៧-លោកស្រី	អ៊ុំ ស៊ីវម៉េង	ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក មន្ទីរកិច្ចការនារីក្រុងកែប
១៨-លោកស្រី	ហួង សារឿន	ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន និងអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីក្រុងកែប
១៩-លោកស្រី	ស្រី ភីនី	ប្រធានការិយាល័យផ្សព្វផ្សាយ មន្ទីរកិច្ចការនារីខេត្តកណ្តាល
២០-លោកស្រី	លឹម ប៊ុនលី	ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ មន្ទីរកិច្ចការនារីខេត្តតាកែវ
២១-លោកស្រី	អ៊ុំ សំអួន	ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារីខេត្តបាត់ដំបង
២២-លោកស្រី	អោ អៀង	ប្រធានការិយាល័យសុខភាព មន្ទីរកិច្ចការនារីខេត្តបាត់ដំបង
២៣-លោកស្រី	ម៉ារី សែម	ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារីខេត្តស្វាយរៀង
២៤-លោកស្រី	ផាត ស៊ិន្ធុរៈនារី	ប្រធានការិយាល័យផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីក្រុងព្រះសីហនុ
២៥-លោកស្រី	អោង អេង	ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ មន្ទីរកិច្ចការ-នារី ខេត្តកោះកុង
២៦-លោកស្រី	តាន់ គឹមច័ន្ទ	ប្រធានការិយាល័យកិច្ចការនារីស្រុកសៀមរាប មន្ទីរកិច្ចនារី ខេត្តសៀមរាប
២៧-លោក	នង សែម	ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ
២៨-លោកស្រី	គី អេងឡាយ	ប្រធានការិយាល័យសុខភាព មន្ទីរកិច្ចការនារីខេត្តពោធិសាត់
២៩-លោកស្រី	កែ អេន	ប្រធានការិយាល័យផែនការ និងស្ថិតិ មន្ទីរកិច្ចការនារីខេត្តកំពង់ចាម
៣០-លោកស្រី	កែវ សំពៅ	ប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ច មន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ
៣១-លោក	ជុំ សុហ៊ាង	ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការ-នារី ខេត្តឧត្តរមានជ័យ
៣២-លោកស្រី	ពៅ គន្ធី	ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការ-នារី ខេត្តកំពត
៣៣-លោកស្រី	លឹម ឈុំ	ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន មន្ទីរកិច្ចការនារី ខេត្តស្ទឹងត្រែង
៣៤-លោកស្រី	ភង នា	ប្រធានការិយាល័យសុខភាព មន្ទីរកិច្ចការនារី ខេត្តរតនគិរី
៣៥-លោកស្រី	សាម៉ី ផាន់នី	ប្រធានមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ខេត្តបន្ទាយមានជ័យ
៣៦-លោកស្រី	ឆេព សុខបូរ៉ាន់	អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារី ខេត្តកំពង់ធំ
៣៧-លោកស្រី	អ៊ីង ស្មី	អនុប្រធានការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ មន្ទីរកិច្ច-ការនារី ខេត្តបន្ទាយមានជ័យ
៣៨-លោកស្រី	ហេង ឃីម	អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីខេត្តសៀមរាប

៣៩-លោកស្រី	នឹម	គសាន	អនុប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស មន្ទីរកិច្ចការនារីខេត្តព្រៃវែង
៤០-លោកស្រី	វ៉ាត់	វង្សៀងហេង	មន្ត្រីការិយាល័យហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មន្ទីរកិច្ចការនារីខេត្តរតនគិរី
៤១-លោកស្រី	យូ	សុភា	មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
៤២-លោក	លី	ពិសិដ្ឋ	មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច
៤៣-លោក	ជិន	ចន	មន្ត្រីនាយកដ្ឋានការពារផ្លូវច្បាប់
៤៤-លោកស្រី	គង់	បូន្នី	មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
៤៥-លោក	នួន	ចាន់រ័ត្ន	មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ x4

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៣៤

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកស្រី **រ៉េហ្ស៊ីន លឺហ្វេ រ៉ូបាំង** (**Régine LEFAIT-ROBIN**) ទីប្រឹក្សាអមក្រសួងសុខាភិបាល នៃគំរោងកម្មវិធីប្រយុទ្ធនឹងជម្ងឺរបេង និង **HIV/AIDS** ដែលបានខិតខំ ស្វះស្វែងរកមូលនិធិ ជាដៃគូ រយៈពេល ០៤ឆ្នាំ កន្លងមក សរុបទឹកប្រាក់ ចំនួន ៥៧៤.២៥៥ ដុល្លារអាមេរិក សំរាប់ដំណើរការកម្មវិធីជួយដល់អ្នកជ្ញុក និងអ្នកជម្ងឺអេដស៍ ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១១៤...អនក្រ.-ទស

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៣

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១១រូប ដែលបានបរិច្ចាគបច្ច័យ និង ធនធាន ចូលរួមជួយកសាង វិទ្យាល័យវិហារសួគ៌ និងសមិទ្ធផលផ្សេងៗ នៅវត្តវិហារសួគ៌ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ជុំ សារុន**	ចៅអធិការវត្តវិហារសួគ៌	បច្ច័យចំនួន ១៥.០០០ ដុល្លារ
២-ព្រះតេជគុណ	**ពេជ្រ ទណ្ណៈ**	គ្រូសូត្រស្តាំវត្តវិហារសួគ៌	បច្ច័យចំនួន ១២.០០០ ដុល្លារ
៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ	**រស់ ឆោម**	អគ្គលេខាធិការរងក្រសួងការពារជាតិ	ថវិកាចំនួន ១០.០០០ ដុល្លារ
៤-លោក	**ប្រាក់ មិន**	អនុប្រធានស្ថាប័នវិស្វករកម្ពុជា	ថវិកាចំនួន ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-លោក	**ម៉េង ឈាងហេង**	មេឃុំវិហារសួគ៌	ថវិកាចំនួន ៥.០២០ ដុល្លារ

គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក	**យន្ត ចំរើ**	សប្បុរសជនភ្នំពេញ	ថវិកាចំនួន ២.៥០០ ដុល្លារ
២-លោក	**អោម ហាក់**	សប្បុរសជន	ថវិកាចំនួន ១.៥០០ ដុល្លារ
៣-លោក	**ចែត ឆាត**	នាយកសាលាបឋមសិក្សាវិហារសួគ៌	ថវិកាចំនួន ១.៣០០ ដុល្លារ

៤-លោក **ឈុន ជុំយ** គណៈកម្មការកសាងវិទ្យាល័យវិហារសួគ៌ ថវិកាចំនួន ១.២០០ ដុល្លារ

៥-លោក **ប៉ុក ឌីម៉ា** គណៈកម្មការកសាងវិទ្យាល័យវិហារសួគ៌ ថវិកាចំនួន ១.១០០ ដុល្លារ

៦-លោក **ចេប ប៊ុនឈឿន** សប្បុរសជន នៅប្រទេសកាណាដា ថវិកាចំនួន ១.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ពានជាតិ

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានចំពាក់ **មេដាយមាសស្ពានជាតិ** ជូនលោកស្រី KUMATA Chie ដែលបានឧបត្ថម្ភថវិកាចំនួន ៣៤.៤៣០ ដុល្លារអាមេរិក សម្រាប់ជួយសាងសង់អគារសិក្សា ០១ខ្នង នៅសាលាមធ្យមសិក្សាត្រពាំងស្វាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនដល់សប្បុរសជន ចំនួន៣រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងដល់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ដូចមានរាយនាមខាងក្រោម ÷

១-លោក **វ័ន្ត សុវណ្ណារ៉ា** នាយផ្នែករដ្ឋបាលព្រៃឈើខេត្តកំពង់ស្ពឺ ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារអាមេរិក

២-លោក **កែវ សុខឃាន** ប្រធានការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ ទីចាត់ការគយ និងរដ្ឋាករ ទឹកប្រាក់ចំនួន ១១.៥០០ ដុល្លារអាមេរិក

៣-លោក **សុខ ខូនថេង** អនិកជនខ្មែររស់នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១១.០០០ ដុល្លារអាមេរិក

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ០៩ អ.យ.ក.ប្រក/០៦

ប្រកាស

ស្តីពី

នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឱ្យលក់ដោយខុសច្បាប់

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ៚

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/០៧ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- អនុលោមតាមមាត្រា៧១ ថ្មី មាត្រា ៧២ និងមាត្រា ៧៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ស ម្រេ ច

ប្រការ ១.-

ប្រគល់តួនាទីជាអាជ្ញាធរដែលត្រូវសម្រេចអំពី ការប្រើប្រាស់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬការពន្យារពេលឱ្យលក់ ជូនមហាអយ្យការអមសាលាឧទ្ធរណ៍ ។

ប្រការ ២.-

សេចក្តីសម្រេចអំពីការប្រើនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬការពន្យារពេលឱ្យលក់ដែលធ្វើតាមករណីនីមួយៗ ត្រូវឱ្យស្របទៅនឹងមាត្រា ៧១ ថ្មី មាត្រា ៧២ និងមាត្រា ៧៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងប្រកាសនេះ ។

ក្នុងករណីបន្ទាន់ដែលចាំបាច់ត្រូវប្រើប្រាស់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល ឬការពន្យារពេលឱ្យលក់ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចលើទីតាំងដែលត្រូវអនុវត្តនីតិវិធីនោះ អាចសម្រេចឱ្យមានការប្រើប្រាស់នីតិវិធីនេះបានក្នុងនាមមហាអយ្យការអមសាលាឧទ្ធរណ៍។ ក្នុងករណីនេះ ព្រះរាជអាជ្ញាដែលចេញសេចក្តីសម្រេចត្រូវជូនដំណឹងភ្លាមទៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

ប្រការ ៣.- អំពីការប្រគល់ដោយមានការឃ្លាំមើល

ក្នុងការអនុវត្តនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើលទៅលើបទល្មើសណាមួយ អាជ្ញាធរអាចសម្រេចឱ្យប្រើប្រាស់ :

- គ្រឿងញៀន ដែលមានចែងនៅក្នុងមាត្រា ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- ឧបករណ៍ បរិក្ខារ ឬសម្ភារៈដទៃៗទៀតដែលជនល្មើសប៉ុនប៉ងយកទៅប្រើប្រាស់ ឬកំពុងប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង
- មូលនិធិ ឬវត្ថុមានតំលៃដទៃៗទៀត ដែលពាក់ព័ន្ធទៅនឹងបទល្មើសណាមួយនោះ ។ ៚

ការប្រើប្រាស់វិធីខាងលើនេះ គឺក្នុងគោលបំណងដើម្បីសម្រួលដល់ការស៊ើបអង្កេតឱ្យមានប្រសិទ្ធភាពដោយអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយដូចជា ការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិតជាមួយជនល្មើសក្នុងអំពើណាមួយ ដើម្បីកំណត់ឱ្យបានច្បាស់អំពីបទល្មើសនោះ និងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់ ។

ប្រសិនបើរដ្ឋបរទេសមានការពាក់ព័ន្ធនៅក្នុងសកម្មភាពនេះ សេចក្តីសម្រេចឱ្យប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើល ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងជាមួយរដ្ឋដែលពាក់ព័ន្ធទាំងនោះ ។

ការជូនដំណឹងអំពីសេចក្តីសម្រេចឱ្យប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើលទៅព្រះរាជអាជ្ញានៃទីកន្លែងដែលត្រូវអនុវត្តសេចក្តីសម្រេចនេះ ត្រូវធ្វើឡើងឱ្យស្របតាមមាត្រា ៧២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក្រៅពីមានសិទ្ធិសម្រេចឱ្យប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវដឹកនាំត្រួតពិនិត្យ និងដាក់បទបញ្ជាឱ្យធ្វើសកម្មភាពណាមួយដែលយល់ឃើញថាសមស្រប និងម្យ៉ាងវិញទៀតក៏មានសិទ្ធិផងដែរក្នុងការពិគ្រោះយោបល់ជាមួយអាជ្ញាធរបរទេស ដែលមានការពាក់ព័ន្ធក្នុងកិច្ចសហប្រតិបត្តិការនិងការអនុវត្តនីតិវិធីនៃការប្រើប្រាស់ការប្រគល់ដោយមានការឃ្លាំមើល ដែលត្រូវធ្វើឡើងក្នុងដែនដីរបស់ខ្លួន ។ អាជ្ញាធរ អាចសម្រេចឱ្យចាំស្កាត់ចាប់យកវត្ថុដែលបញ្ជូនមកខុសច្បាប់ ហើយដាក់ជំនួសវិញដោយវត្ថុផ្សេងមុនពេលបញ្ជូនបន្ត ។ ក្នុងករណីការអនុវត្តនីតិវិធីការប្រគល់ដោយមានការឃ្លាំមើលដែលមានលក្ខណៈជាអន្តរជាតិ វិធានការអនុវត្តអាចសម្រេចបានទៅតាមកិច្ចព្រមព្រៀងជាមួយរដ្ឋបរទេស ដែលមានផលប្រយោជន៍ពាក់ព័ន្ធក្នុងករណីនីមួយៗ ។

មន្ត្រីអនុវត្តច្បាប់នីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល អាចបញ្ជាឱ្យធ្វើអន្តរាគមន៍នៅគ្រប់ដំណាក់កាលទាំងអស់នៃប្រតិបត្តិការរបស់ខ្លួន ប្រសិនបើត្រូវការទប់ស្កាត់ភាពអសន្តិសុខភ្លាមៗ ឬមានការផ្លាស់ប្តូរទិសដៅនៃការបញ្ជូនដែលមិនបានរំពឹងទុកជាមុនបាន ឬមានកាលៈទេសៈផ្សេងៗទៀតដែលជាឧបសគ្គដល់ការរឹបអូសវត្ថុបញ្ជូន ឬឱ្យធ្វើសកម្មភាពស្របច្បាប់ណាមួយសម្រាប់តទល់នឹងជនល្មើស ។

ប្រការ ៤.- អំពីការញុះញង់ឱ្យលក់ដោយខុសច្បាប់

អាជ្ញាធរអាចសម្រេចប្រគល់សិទ្ធិដល់មន្ត្រីអនុវត្តច្បាប់ណាមួយ ឱ្យធ្វើការញុះញង់ជនទាំងឡាយណាដែលមានមូលហេតុធួនល្មមសង្ស័យថាបានប្រព្រឹត្ត កំពុងប្រព្រឹត្ត ឬរៀបចំប្រព្រឹត្តបទល្មើសទាក់ទងទៅនឹងគ្រឿងញៀនដើម្បីឱ្យជននោះលក់ដោយខុសច្បាប់នូវ : ។ ៚

- គ្រឿងញៀន ឬសារធាតុដទៃៗទៀត ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង
- ឧបករណ៍ បរិក្ខារ ឬសំភារៈដទៃៗទៀតដែលជនល្មើសមានចេតនាយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ការប្រើប្រាស់វិធីខាងលើនេះ គឺក្នុងគោលបំណងដើម្បីសម្រួលដល់ការស៊ើបអង្កេតឱ្យមានប្រសិទ្ធភាព ដោយអនុញ្ញាតឱ្យមន្ត្រីមានសមត្ថកិច្ចចូលរួមក្នុងបទល្មើសទាំងឡាយ ដូចជា ការទំនាក់ទំនង ការឃុបឃិត ការប៉ុនប៉ង ឬការសមគំនិតជាមួយជនល្មើសក្នុងអំពើណាមួយ ដើម្បីកំណត់ឱ្យបានច្បាស់អំពីបទល្មើសនោះ និងជនពាក់ព័ន្ធដែលត្រូវធ្វើការចោទប្រកាន់ ។

នៅពេលសម្រេចឱ្យប្រើប្រាស់វិធីនេះ អាជ្ញាធរត្រូវពិចារណាឱ្យបានហ្មត់ចត់ មួយផ្អែកទៅលើភស្តុតាងដែលបានប្រមូល និងមួយផ្អែកទៀតទៅលើលទ្ធភាពផ្សេងៗ ដែលជាការប្រថុយប្រថានទៅនឹងគ្រោះថ្នាក់របស់បុគ្គលដែលមានការពាក់ព័ន្ធក្នុងសកម្មភាពល្មើស ដែលតាមធម្មតា ប្រសិនជាយើងមិនញុះញង់ទេ គេពុំធ្វើដូច្នោះឡើយ ។

វិធីដូចបានកំណត់ក្នុងកថាខ័ណ្ឌខាងលើនេះ អាចអនុវត្តបានដោយបុគ្គលឯកជនធម្មតាក្រោមបញ្ជា និងក្រោមការត្រួតពិនិត្យផ្ទាល់របស់មន្ត្រីអនុវត្តច្បាប់ដែលបានចាត់តាំង ។

មន្ត្រីអនុវត្តច្បាប់ ឬបុគ្គលធម្មតាដែលបានទទួលការចាត់តាំងឱ្យអនុវត្តវិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ស្របទៅតាមកថាខ័ណ្ឌខាងលើនៃប្រការនេះ ឬប្រការ ៣ នៃប្រកាសនេះ មិនត្រូវទទួលនូវការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល ឬផ្នែករដ្ឋប្បវេណី ចំពោះសកម្មភាពទាំងឡាយដែលខ្លួនបានធ្វើក្នុងវង្វង់សិទ្ធិដែលបានអនុញ្ញាតឡើយ ។

អនុលោមតាមមាត្រា ៧២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន សេចក្តីសម្រេចរបស់អាជ្ញាធរដែលអនុញ្ញាតឱ្យប្រើប្រាស់វិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ ត្រូវជូនដំណឹងភ្លាមទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចលើទីកន្លែងដែលអាចសន្មតថាការលក់នោះនឹងត្រូវធ្វើឡើង ។

ប្រតិបត្តិការសេចក្តីសម្រេចរបស់អាជ្ញាធរ ដែលអនុញ្ញាតឱ្យប្រើប្រាស់វិធីញុះញង់ឱ្យលក់ដោយខុសច្បាប់ត្រូវស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលសិទ្ធិធ្វើការត្រួតពិនិត្យ និងស្រាវជ្រាវដើម្បីបង្ក្រាបបទល្មើស ដូចមានចែងក្នុងមាត្រា ១១០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន អាចចេញបទបញ្ជានូវវិធានការសមស្របដើម្បីឱ្យការអនុវត្តន៍នេះទទួលបានជោគជ័យ ។ ៥

ប្រការ ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.-

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

អង្គ វង្សវឌ្ឍានះ

ចំលងជូន

- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- គ្រប់អយ្យការ និងតុលាការខេត្ត-ក្រុង
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១៧១ ឧរថ.កន.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២០៤៧/០៥ គ.វ.ក ចុះថ្ងៃទី ២៣.០៦.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត ចុះថ្ងៃទី១៩.០៥.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត (PHNOM PENH SUPPLY COMPANY LIMITED) តំណាងដោយលោក PORNSAKDI NOPPORNPROM សញ្ជាតិថៃ អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ K687474 ចុះថ្ងៃទី១១.០១.២០០៦ បង្កើតរោងចក្រ " ប្លាស្ទិក " ដែលមានឈ្មោះថា " ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីតធីត (PHNOM PENH SUPPLY COMPANY LIMITED)" មានទីតាំងស្ថិតនៅ ឃុំប៉ោយប៉ែត ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855 23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យផលិត "ស្បោង និងសំបកផលិតផលប្លាស្ទិក" ហើយត្រូវធ្វើរបាយការណ៍ ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តបន្ទាយមានជ័យ និងប្រធានក្រុមហ៊ុន ភ្នំពេញ សាប់ផ្លាយ ខមផេនី លីមីធីត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តបន្ទាយមានជ័យ

"ដើម្បីជូនជ្រាប"
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៧៧២ ឧស.-ក.ប.-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ ២០០៧

ប្រ ក ា ស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៤១/០៦ គ.វ.ក ចុះថ្ងៃទី១៩.១០.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុម ហ៊ុយចៀន (ខេមបូឌា) ខប ចុះថ្ងៃទី៣០.១២.២០០៥

ស ំ រ េ ច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប (HUEY CHUEN (CAMBODIA) CORP., LTD. តំណាងដោយ លោក WANG, WEN-SHIH សញ្ជាតិចិន(តៃវ៉ាន់) អាយុ៦០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131196173 ចុះថ្ងៃទី០៥.០២.២០០១ បង្កើតរោងចក្រ "ផលិតស្បែកជើង"ដែលមានឈ្មោះថា "ហ៊ុយចៀន (ខេមបូឌា) ខប (HUEY CHUEN (CAMBODIA) CORP)" មានទីតាំងស្ថិតនៅ ផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១៧៣ ឧរ៥.ករ.ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០៧០/០៦ គ.វ.ក ចុះថ្ងៃទី ០៤.០១.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អេច ២ ហ្គាមេន ចុះថ្ងៃទី១៣.១២.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អេច ២ ហ្គាមេន (H2 GARMENT CO., LTD.) តំណាងដោយលោក LIN, HUNG-YANG សញ្ជាតិចិន តៃវ៉ាន់ អាយុ២៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 211463266 ចុះថ្ងៃទី០៤.០៨.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "អេច ២ ហ្គាមេន (H 2 GARMENT)" មានទីតាំងស្ថិតនៅ ភូមិឡក់បោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "ផលិតស្បែកជើង" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះខនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ហ៊ុយចេន (ខេមបូឌា) ខប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឹងម៉ាត់ នូវច្បាប់ និង បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន អេច ២ ហ្គាមេន ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០៩៣ ឧ.រ.ថ ក.ព.ក

រាជធានីភ្នំពេញ. ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥០៧១/០៥ គ.វ.ក ចុះថ្ងៃទី២១.១២.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន តាលិន ហ្គាមេន អ៊ិនដាសស្ទ្រី (ខេមបូឌា) ចុះថ្ងៃទី១៤.១២.២០០៥

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន តាលិន ហ្គាមេន អ៊ិនដាសស្ទ្រី (ខេមបូឌា) (TALENT GARMENT INDUSTRY (CAMBODIA) CO., LTD.) តំណាងដោយ លោក FANG SHIJUN សញ្ជាតិចិន អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខG11591813 ចុះថ្ងៃទី០៩.១១.២០០៤បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់"ដែលមានឈ្មោះថា " តាលិន ហ្គាមេន អ៊ិនដាសស្ទ្រី (ខេមបូឌា) (TALENT GARMENT INDUSTRY (CAMBODIA))" មានទីតាំងស្ថិតនៅ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ “កាត់ដេរសម្លៀកបំពាក់” ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ ” របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន តាលិន ហ្គាមេន អ៊ិនដាសស្ទ្រី (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

“ ដើម្បីជូនជ្រាប ”

- ដូចប្រការ ៩ “ ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ១៤៥ អយក.ប្រក

ប្រកាស

ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន " **ឌួនហ្វា II** "

ស្ថិតនៅក្នុង សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់ លោកឧកញ៉ា ដួង ឈីវ ចុះថ្ងៃទី ០៦ ធ្នូ ២០០៥ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ១ : អនុញ្ញាតឱ្យពង្រីកសាលាចំណេះទូទៅឯកជន " **ឌួនហ្វា II** " ចាប់ពីកំរិតបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ស្ថិតនៅក្នុងសង្កាត់ អូឡាំពិក ខណ្ឌ ចំការមន រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ២ : សាលារៀនចំណេះទូទៅឯកជន **ឌួនហ្វា II** ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ៣ : លោកឧកញ៉ា **ដួង ឈីវ** ជានាយកសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវក្នុងការងារ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សឱ្យចូលរៀន ។
- ធានាដំណើរការបង្រៀន និងរៀនឱ្យបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញតាមកាលកំណត់ ។

ប្រការ៤ : ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

